# សុន្ទរកថា
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីបិទមហាសន្និបាតបូកសរុបការងារ និង បិទបញ្ចប់អាណត្តិទី ៤ របស់សហព័ន្ធស្រូវ-អង្ករកម្ពុជា

រាជធានីភ្នំពេញ, ថ្ងៃ អង្គារ ៣ កើត, ខែភទ្របទ, ឆ្នាំម្សាញ់, សប្តស័ក ព.ស. ២៥៦៩

ត្រូវនឹងថ្ងៃទី ២៦ ខែ សីហា គ.ស. ២០២៥, សណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា

****+*****

- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, ថ្នាក់ដឹកនាំ និង តំណាង នៃក្រសួង-ស្ថាប័ន;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, ជាថ្នាក់ដឹកនាំនៃសហព័ន្ធស្រូវ-អង្ករកម្ពុជា, តំណាងវិស័យឯកជន, សមាជិក-សមាជិកា នៃអង្គពិធី, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួម ជាអធិបតីក្នុងពិធីបិទ **មហាសន្និបាតបូកសរុបការងារ និង បិទបញ្ចប់ អាណត្តិទី ៤ របស់សហព័ន្ធស្រូវ-អង្ករកម្ពុជា** ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីដ៏មានសារៈសំខាន់, តាំងពីព្រឹក រហូតដល់កម្មវិធីបិទ, នាឱកាសនេះ ។

ខ្ញុំសូមចូលរួមសម្តែង នូវការអបអរសាទរ ចំពោះថ្នាក់ដឹកនាំនៃសហព័ន្ធស្រូវ-អង្ករកម្ពុជា, អាណត្តិទី ៥, ដែលទើបត្រូវបានសមាជិក-សមាជិកានៃសហព័ន្ធ បោះឆ្នោតប្រគល់ការទុកចិត្ត ក្នុងនោះ រួមមាន៖ **ឧកញ៉ា ចាន់ សុឃាំង** ជាប្រធានក្រុមប្រឹក្សាភិបាល និង **ឧកញ៉ា ឡាយ ឈុនហួរ** ជាប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា ។ ទន្ទឹមនេះ, ខ្ញុំក៏សូមសម្តែង

នូវអំណរគុណយ៉ាងជ្រាលជ្រៅ និង ការវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំទាំងឡាយ របស់សហព័ន្ធស្រូវ-អង្ករកម្ពុជា, ក្នុងអាណត្តិទី ៤ កន្លងទៅ, ដែលសម្រេចបាននូវសមិទ្ធផលជាច្រើន គួរឲ្យកត់សម្គាល់ ។

ការរៀបចំមហាសន្និបាតបូកសរុបការងារ និង បិទបញ្ចប់អាណត្តិទី ៤ របស់សហព័ន្ធស្រូវ-អង្ករកម្ពុជា នាថ្ងៃនេះ ពិតជាបានផ្តល់នូវឱកាសដ៏ប្រពៃ ក្នុងការរួមគ្នាអបអរសាទរសមិទ្ធផលការងារ ដែលសហព័ន្ធស្រូវ-អង្ករកម្ពុជា ប្រឹងប្រែងសម្រេចបាន ក្នុងអាណត្តិ ទី ៤, ទន្ទឹមនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល និង ថ្នាក់ដឹកនាំសហព័ន្ធស្រូវ-អង្ករកម្ពុជា សម្រាប់អាណត្តិទី ៥, ដើម្បីកំណត់ទិសដៅការងារ ក្នុងការបន្តជំរុញ និង អភិវឌ្ឍន៍វិស័យស្រូវ-អង្ករកម្ពុជា ឆ្ពោះទៅសម្រេចគោលដៅនៃការនាំចេញអង្ករ ឲ្យបាន ១ លានតោន ក្នុងមួយឆ្នាំ ស្របតាម **«យុទ្ធសាស្ត្រពង្រីក និង ពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា ២០២៥-២០៣០»**, ដែលលោកជំទាវ **ចម និម្មល**, រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, ទើបបានប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ កាលពីព្រឹកមិញ ។

ឆ្លៀតក្នុងឱកាសដ៏កម្រនេះ, ខ្ញុំសូមកត់សម្គាល់ ដោយមោទកភាព ចំពោះកិច្ច-សហប្រតិបត្តិការដ៏ល្អ, ដែលត្រូវបានឆ្លុះបញ្ចាំង តាមរយៈការសហការរៀបចំកម្មវិធីមហា-សន្និបាតនេះ, រវាងសហព័ន្ធស្រូវ-អង្ករកម្ពុជា, ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម, ព្រមទាំង ដៃគូពាក់ព័ន្ធជាច្រើនទៀត ។ ការណ៍នេះ បានបង្ហាញឲ្យឃើញច្បាស់នូវការរួបរួមគ្នាជាធ្លុងមួយដ៏រឹងមាំ ដើម្បីជួយគ្នាក្នុងការដោះស្រាយបញ្ហាប្រឈមផងទាំងពួង ក្នុងវិស័យស្រូវ-អង្ករ, ទាំងក្នុងបច្ចុប្បន្ន និង ទៅអនាគត ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

រាជរដ្ឋាភិបាលកម្ពុជា បន្តចាត់ទុកវិស័យស្រូវ-អង្ករ ជាអាទិភាព ដ៏មានសារៈ-សំខាន់, ដែលមិនត្រឹមតែ ដើម្បីធានានូវសន្តិសុខស្បៀងប៉ុណ្ណោះទេ, ប៉ុន្តែថែមទាំង ដើម្បីបង្កើនល្បឿននៃការកាត់បន្ថយភាពក្រីក្រ, ការលើកកម្ពស់ជីវភាពប្រជាជន និង ការជំរុញកំណើនសេដ្ឋកិច្ចជាតិ ទៀតផង ។ ជាក់ស្តែង, ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, វិស័យដំណាំស្រូវនៅកម្ពុជា មានការរីកចម្រើន គួរឲ្យកត់សម្គាល់, ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃផ្ទៃដីដាំដុះ, បរិមាណផល, ទិន្នផល និង គុណភាព, ដោយផ្លាស់ប្តូរពីផលិតកម្មបែប **«បើកទូលាយ»** ឬ **«វិបុលកម្ម»**, ទៅជាបែប **«ស៊ីជម្រៅ»** ឬ

«**ប្រពលកម្ម**», តាមរយៈការពង្រឹងសមត្ថភាពដាំដុះ លើផ្ទៃដីដែលមានស្រាប់ ដោយប្រើប្រាស់ធាតុចូលកសិកម្ម, ការគ្រប់គ្រងទឹក និង ការប្រើប្រាស់គ្រឿងយន្ត ។ល។

ការសម្រេចបាននូវភាពជោគជ័យ ក្នុងផលិតកម្មស្រូវ បានផ្តល់កាលានុវត្តភាពដល់កម្ពុជា ក្នុងការចាប់ផ្តើមនាំចេញអង្ករ ជាលើកដំបូង ក្នុងឆ្នាំ ២០០៨ ។ ចាប់តាំងពីពេលនោះមក, បរិមាណនៃការនាំចេញអង្កររបស់កម្ពុជា បានកើនគួរឲ្យកត់សម្គាល់, ដូចឯកឧត្តម **ឌិត ទីណា**, រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, បានធ្វើការចាប់អារម្មណ៍នៅមុននេះបន្តិច ។ ការលូតលាស់ដ៏ប្រសើរនេះ គឺជាសមិទ្ធផលនៃការចូលរួមចំណែកពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធ ក្នុងខ្សែច្រវាក់តម្លៃ, រាប់ចាប់ពីកសិករខ្នាតតូច, សហគមន៍ដាំដុះ, រោងម៉ាស៊ីនកិនស្រូវ, ក្រុមហ៊ុននាំចេញអង្ករ, ជាពិសេស សហព័ន្ធស្រូវ-អង្ករកម្ពុជាផ្ទាល់, ដែលបានធ្វើការយ៉ាងសកម្ម និង ប្រកបដោយភាពបុរេសកម្ម ។

ខ្ញុំសូមរម្លឹកឡើងវិញបន្តិចថា ការសម្រេចបានលទ្ធផលដ៏ល្អខាងលើ កើតចេញពីការចង្អុលបង្ហាញដ៏ត្រឹមត្រូវ និង មុតស្រួច របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្ន ជាប្រធានព្រឹទ្ធសភា**, ដោយ **សម្តេច** បានប្រសិទ្ធនាម «**អង្ករ**» ជា «**មាស ស**» ដែលកម្ពុជាអាចទាញយកប្រយោជន៍បានយ៉ាងច្រើន ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និង លើកកម្ពស់ជីវភាពប្រជាជន, តាមរយៈការដាក់ចេញនូវ «**កម្មវិធីគោលនយោបាយ ស្តីពីការជំរុញផលិតកម្មស្រូវ និង ការនាំចេញអង្ករ**» នៅឆ្នាំ ២០១០, ស្របតាមទិសដៅគោលនយោបាយ នៃ «**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២**», សំដៅលើកកម្ពស់ផលិតភាព, ពិពិធភាវូបនីយកម្ម, និង ពាណិជ្ជូបនីយកម្មកសិកម្ម ដែលនៅតែជាមូលដ្ឋានគ្រឹះ ក្នុងការកំណត់ទិសដៅនៃការអភិវឌ្ឍវិស័យស្រូវ-អង្ករ រហូតមកដល់បច្ចុប្បន្ន ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

កម្ពុជាបន្តសម្រេចបាន នូវសមិទ្ធផលដ៏ធំធេងជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលធ្វើឲ្យប្រទេស និង ជាតិយើង ទទួលបាននូវការផ្លាស់ប្តូរមុខមាត់ គួរជាទីមោទនៈ ។ លើសពីនេះ, កម្ពុជាក៏ធានាបាន នូវសន្តិសុខ, សុវត្ថិភាព, សណ្តាប់ធ្នាប់សង្គម និង ស្ថិរភាពនយោបាយ, ព្រមទាំង រក្សាបានយ៉ាងល្អ នូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ; ពោលគឺ កម្ពុជាបានក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេស ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់, ក្នុងអត្រាកំណើន ជាមធ្យមជាង **៧ ភាគរយ ក្នុងមួយឆ្នាំ** ក្នុងរយៈពេលជាងពីរទសវត្សរ៍ នៃដំណាក់កាលមុនវិបត្តិនៃជំងឺកូវីដ-១៩ ។ តាមរយៈការដាក់ចេញ និង ការជំរុញ

អនុវត្តយ៉ាងសកម្ម និង ទាន់ពេល នូវគោលនយោបាយត្រឹមត្រូវ, មុតស្រួច និង ចំទិសដៅរបស់រាជរដ្ឋាភិបាល នៅតាមវិស័យសំខាន់ៗទាំងឡាយ, សេដ្ឋកិច្ចកម្ពុជា, ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, បានស្ទុះងើបឡើងវិញយ៉ាងរហ័ស និង បន្តឈរលើមាគ៌ានៃកំណើនដ៏រឹងមាំ បន្ទាប់ពីវិបត្តិជាសកលនេះ ទោះបីជាត្រូវបន្តពុះពារជម្នះ នូវបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពសកល ដោយសារការបន្តប្រឈមមុខខាងភូមិសាស្ត្រនយោបាយ កាន់តែស្រួចស្រាល់; ការបែកខ្ញែកនៃសេដ្ឋកិច្ចសកល ដែលប៉ះពាល់ដល់កិច្ចសហប្រតិបត្តិការ និង ពាណិជ្ជកម្មអន្តរជាតិ; ការងើបមកវិញនៃនិន្នាការឯកតោភាគីនិយម; ភាពមិនច្បាស់លាស់នៃទស្សនវិស័យនៃកំណើនសេដ្ឋកិច្ច នៃបណ្តាប្រទេស និងតំបន់ ជាដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា ។ល។

ក្នុងឆ្នាំ ២០២៥ នេះ, ការដាក់ពន្ធគយបដិការ របស់សហរដ្ឋអាម៉េរិក និង ការផ្ទុះឡើង នូវជម្លោះព្រំដែនដែលបង្កឡើង ដោយប្រទេសជិតខាងរបស់កម្ពុជា នាពេលថ្មីៗនេះ បានបន្ថែមសម្ពាធ មកលើសេដ្ឋកិច្ចកម្ពុជា ។ នៅចំពោះមុខបញ្ហាប្រឈមទាំងនេះ, ទន្ទឹមនឹងការឆ្លើយតបដោយម៉ឺងម៉ាត់ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការការពារអធិបតេយ្យ, បូរណភាពដែនដី និង កិត្យានុភាពជាតិ, រាជរដ្ឋាភិបាល, ក្រោមការដឹកនាំដ៏ឈ្លាសវៃ និង ប៉ិនប្រសប់ ប្រកបដោយជវភាព របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, បាន និង កំពុង តាមដាន និង វាយតម្លៃស្ថានការណ៍ជាក់ស្តែង ដោយយកចិត្តទុកដាក់បំផុត ព្រមទាំង ថ្លឹងថ្លែង និង ត្រៀមដាក់ចេញ នូវវិធានការឆ្លើយតបមុតស្រួច លើគ្រប់វិស័យទាំងឡាយ សំដៅ, ម្ខាង, រក្សាចលនការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជារួម; និង ម្ខាងទៀត, ប្រែក្លាយបញ្ហាប្រឈមទាំងនេះឲ្យក្លាយទៅជាកាលានុវត្តភាព, ជាពិសេស សម្រាប់ការលើកកម្ពស់សហគ្រាសធុនតូច, និង មធ្យម, ខណៈដែលស្មារតីស្នេហាជាតិ និង ចលនារួបរួមជាតិ កាន់តែមានសន្ទុះខ្លាំងឡើង, ដែលជំរុញដល់ការលើកស្ទួយ និង ការឲ្យតម្លៃខ្ពស់ ដល់ផលិតផលក្នុងស្រុក ។ ការណ៍នេះ គឺជាកាលានុវត្តភាពមួយដ៏វិសេស សម្រាប់ការអភិវឌ្ឍសមត្ថភាព, ការធ្វើពិពិធកម្មផលិតផលក្នុងស្រុក, និង ការពង្រឹងឧត្តមភាពប្រកួតប្រជែងរបស់កម្ពុជា ដែលនឹងរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច និង ការពង្រឹងឯករាជ្យភាពនៃសេដ្ឋកិច្ចជាតិ ។ និយាយជារួម, រាជរដ្ឋាភិបាល នឹងបន្តពង្រឹងភាពប្រកួតប្រជែង, ភាពរឹងមាំ និង ភាពធន់ទៅនឹងវិបត្តិ តាមរយៈការកែលម្អបរិយាកាសធុរកិច្ច, ការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងលទ្ធភាពលើកកម្ពស់ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងស្រុក សំដៅជំរុញការតភ្ជាប់ ទៅនឹង

ខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និង សកល, ការចាប់យកសកម្មភាពផលិតកម្មដែលបង្កើតតម្លៃបន្ថែមខ្ពស់, ការបង្កើតការងារសម្រាប់កម្លាំងពលកម្មដែលមានជំនាញ, ការពង្រីកមូលដ្ឋានសេដ្ឋកិច្ចជាតិ ឲ្យកាន់តែទូលំទូលាយ ។ល។ ជាលទ្ធផល, ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ច ៧ ខែ ដើមឆ្នាំ ២០២៥, សេដ្ឋកិច្ចកម្ពុជា នៅបន្តមានចលនការល្អ, ដោយក្នុងនោះ, ទោះបីវិស័យខ្លះហាក់មិនទាន់អាចស្ទុះងើបខ្លាំង ដូចការរំពឹងទុក, ប៉ុន្តែ វិស័យមួយចំនួនក៏សម្រេចបានវឌ្ឍនភាពល្អជាងការរំពឹងទុក; ខណៈវិស័យកសិកម្ម នៅបន្តរក្សាបាននូវស្ថិរភាពនៃកំណើន ។ និយាយដោយឡែក, ចំពោះវិស័យស្រូវ-អង្ករ, រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៧ នេះ នៃរដ្ឋសភា នៅតែបន្តយកចិត្តទុកដាក់ខ្ពស់, ដូចនីតិកាលមុនៗផងដែរ, ដែលការណ៍នេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ ក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។ ជាក់ស្តែង, រាជរដ្ឋាភិបាល បាន និង កំពុងផ្តល់ការគាំទ្រ និង ធ្វើអន្តរាគមន៍យ៉ាងសកម្មចំពោះវិស័យស្រូវ-អង្ករ តាមរយៈវិធានការគន្លឹះមួយចំនួន រួមមាន ជាអាទិ៍៖

**ទី១.** ការដាក់ចេញនូវយន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទានពិសេស សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផល, តាមរយៈការផ្តល់នូវកញ្ចប់ថវិកា ចំនួន ១០០ លានដុល្លារអាមេរិក, ដើម្បីធ្វើអន្តរាគមន៍ឲ្យបានទាន់ពេល ក្នុងការប្រមូលទិញកសិផល, ជាពិសេស ស្រូវ, សំដៅរក្សាស្ថិរភាពថ្លៃ និង ធានាសន្តិសុខស្បៀង ។ ត្រង់ចំណុចនេះ, ខ្ញុំសូមគូសបញ្ជាក់ថា ក្រោមកម្មវិធីហិរញ្ញប្បទានពិសេសនេះ, រាជរដ្ឋាភិបាល បានអនុញ្ញាតឲ្យធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) ប្រើប្រាស់មូលនិធិចំនួន ៧០ លានដុល្លារអាមេរិក កាលពីឆ្នាំ ២០២៤ កន្លងទៅ ។ ថ្មីៗនេះ, រាជរដ្ឋាភិបាល ក៏បានសម្រេចដកថវិកា ចំនួន ២០ លានដុល្លារអាមេរិក ពីមូលនិធិនេះ ឲ្យ ARDB ដើម្បីផ្តល់ជាទុនបង្វិលដល់រោងម៉ាស៊ីនកិនស្រូវ ក្នុងការប្រមូលទិញស្រូវពីប្រជាកសិករ ក្នុងតម្លៃសមរម្យ ។ គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, តាមរយៈក្រុមការងារបច្ចេកទេសអន្តរក្រសួង ដែលទើបត្រូវបានបង្កើតឡើងថ្មី, នឹងបន្តតាមដានសភាពការណ៍ទីផ្សារស្រូវ-អង្ករ ជាប់ជាប្រចាំ បន្តទៅទៀត, ហើយនឹងសម្របសម្រួលស្នើឡើង នូវវិធានការចាំបាច់នានា សំដៅដោះស្រាយបញ្ហាទីផ្សារ និង ថ្លៃកសិផល ឲ្យបានសមស្រប និង ទាន់ពេល ។

**ទី២.** ការដាក់ពង្រាយមន្ត្រីកសិកម្មនៅតាមឃុំ/សង្កាត់ ក្រោមការរៀបចំរបស់ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** សំដៅបង្វិតសេវាកសិកម្ម ឲ្យបានទៅជិតប្រជាពលរដ្ឋ

នៅមូលដ្ឋានឃុំទាំងអស់នៅជនបទទូទាំងប្រទេស ដើម្បីជួយដល់គ្រួសារកសិករ ក្នុងការ-លើកស្ទួយផលិតភាពកសិកម្ម និង ប្រាក់ចំណូល ។

**ទី៣.** ការផ្តល់ឥណទានជាមួយអត្រាការប្រាក់សមរម្យ និង លក្ខខណ្ឌអនុគ្រោះ ដល់វិស័យស្រូវ-អង្ករ តាមរយៈ **ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម** សម្រាប់ការ-វិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធរោងម៉ាស៊ីនកិនស្រូវ, ឃ្លាំង និង ឡសម្ងួត ។

**ទី៤. ការលើកកម្ពស់លទ្ធភាពទទួលបានឥណទានបន្ថែម ពីធនាគារឯកជន** តាមរយៈ យន្តការធានាឥណទាន របស់ **សាជីវកម្មធានាឥណទានកម្ពុជា** ក្រោមគម្រោងធានាឥណ-ទាន សម្រាប់ការនាំចេញអង្ករ ដែលកន្លងមក បានផ្តល់ការធានាលើកម្ចី សរុបប្រមាណ ៣៨ លានដុល្លារអាមេរិក ។

**ទី៥.** ការផ្តល់ការលើកទឹកចិត្ត ដល់វិស័យស្រូវ-អង្ករ តាមរយៈការលើកលែងពន្ធគយ លើការនាំចូលសម្ភារៈបរិក្ខារ និង ការផ្តល់ការអនុគ្រោះ ខាងពន្ធដារ រួមបញ្ចូលនូវការដាក់ ជាបន្ទុករបស់រដ្ឋ នូវអាករលើតម្លៃបន្ថែម, ព្រមទាំងការព្យួរទុក នូវការបង់ពន្ធអប្បបរមា និង ការបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ។ ពាក់ព័ន្ធចំណុចនេះ, សហព័ន្ធស្រូវ-អង្ករ ក៏បានស្នើសុំមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបន្តផ្តល់ការលើកទឹកចិត្ត ផ្នែក ពន្ធដារ ចំពោះវិស័យស្រូវ-អង្ករ សម្រាប់រយៈពេល ៥ ឆ្នាំ បន្ថែមទៀត ។ ខ្ញុំសូមគូសបញ្ជាក់ ថា, ជាគោលការណ៍, រាជរដ្ឋាភិបាល, តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, បាន ដាក់ចេញនូវប្រកាសលេខ ១៧០ សហវ.ប្រក.អពជ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២៤ ស្តីពីការលើកទឹកចិត្តពន្ធដារ ចំពោះវិស័យកសិកម្ម ដែលនឹងត្រូវអស់សុពលភាព នៅ ដំណាច់ឆ្នាំ ២០២៥ ខាងមុខនេះ ។ យ៉ាងណាមិញ, ផ្អែកតាមតម្រូវការចាំបាច់ជាក់ស្តែង ចំពោះមុខ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពីប្រមុខ រាជរដ្ឋាភិបាល ដើម្បីបន្តសុពលភាពប្រកាសខាងលើ សម្រាប់រយៈពេល ២ ឆ្នាំ បន្ថែម ទៀត ។ បន្ទាប់ពីនោះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងពិនិត្យ និង វាយតម្លៃស្ថាន ការណ៍ជាក់ស្តែង ដើម្បីពិនិត្យលទ្ធភាពបន្តសុពលភាព នៃការផ្តល់ការលើកទឹកចិត្តផ្នែក ពន្ធដារ ចំពោះវិស័យ កសិកម្មបន្ថែមទៀត ក្នុងករណីចាំបាច់ ។

**ទី៦.** ការធ្វើពិពិធកម្មទីផ្សារនាំចេញអង្កររបស់កម្ពុជា ក្រោមការដឹកនាំ របស់ **ក្រសួង ពាណិជ្ជកម្ម** ដែលបានខិតខំបើកទីផ្សារនាំចេញថ្មីបន្ថែម ក៏ដូចជា ការលើកកម្ពស់កិច្ច-សហប្រតិបត្តិការពាណិជ្ជកម្ម ជាមួយដៃគូពាណិជ្ជកម្មធំៗ និង ការចរចាកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរី ជាមួយបណ្តាប្រទេសធំៗមួយចំនួនផងដែរ ។

**ទី៧.** កិច្ចប្រឹងប្រែង របស់ **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** ក្នុងការអភិវឌ្ឍពូជស្រូវ រហូតទទួលបានពានរង្វាន់អង្ករល្អបំផុត លើពិភពលោក ចំនួន ៦ លើក និង ក្នុងការចងក្រងសហគមន៍កសិកម្មទំនើប ដើម្បីប្រែក្លាយវិស័យកសិកម្មកម្ពុជា, ពីលក្ខណៈគ្រួសារទៅជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដ៏រឹងមាំ, ដែលមានសមាហរណកម្មខ្ពស់, មានសេដ្ឋកិច្ចមាត្រដ្ឋាន និង មានសមត្ថភាពប្រកួតប្រជែង, ទាំងបរិមាណ និង គុណភាព ។

**ទី៨.** ការគាំទ្ររបស់ **សហគ្រិនខ្មែរ** (Khmer Enterprise) ក្រោមការដឹកនាំ របស់ **ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍** ក្នុងការជំរុញការផ្សព្វផ្សាយអង្ករកម្ពុជា ក្នុងវេទិកាអន្តរជាតិនានា ។ និង

**ទី៩.** ការចូលរួមកាត់បន្ថយថ្លៃដើមផលិតកម្ម ក្នុងការកែច្នៃអង្ករ តាមរយៈការបញ្ចុះថ្លៃអគ្គិសនីដល់រោងម៉ាស៊ីនកិនស្រូវ សម្រាប់ប្រតិបត្តិការសម្ងួត និង កែច្នៃអង្ករ ក្នុងរដូវប្រមូលផល ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងរបាយការណ៍ស្វាគមន៍, មតិប្តេជ្ញាចិត្ត និង ចំណាប់អារម្មណ៍របស់ខ្លួន នៅមុននេះបន្តិច, ឯកឧត្តម និង លោកជំទាវ ជាវាគ្មិន បានវាយតម្លៃអំពីស្ថានភាព និង បានគូស-បញ្ជាក់ អំពីបញ្ហាប្រឈម និង បានស្នើនូវវិធានការមួយចំនួន ដើម្បីជំរុញការអភិវឌ្ឍវិស័យស្រូវ-អង្ករកម្ពុជា, ជាពិសេស **វិធានការយុទ្ធសាស្ត្រ ទាំង ៦** ដែលត្រូវបានដាក់ចេញ ក្នុង **«យុទ្ធសាស្ត្រពង្រីក និង ពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា ២០២៥-២០៣០»**, ដែលលោកជំទាវរដ្ឋមន្ត្រី **ចម និម្មល** បានគូសរំលេចមុននេះ ។

ខ្ញុំសូមធ្វើការកត់សម្គាល់ថា ស្ថានភាពនៃវិស័យស្រូវ-អង្ករ មានការវិវត្តជាប្រចាំ, ហើយមានលក្ខណៈខុសៗគ្នា ពីមួយឆ្នាំ ទៅមួយឆ្នាំ, ដែលទាមទារឲ្យភាគីពាក់ព័ន្ធទាំងឡាយតាមដានជានិច្ច និង រួមគ្នាចាត់វិធានការឲ្យចំទិសដៅ ដើម្បីឆ្លើយតបទៅតាមសភាពការណ៍ជាក់ស្តែង ក្នុងឆ្នាំនីមួយៗផង និង ដោះស្រាយកម្មវិបាក ក្នុងឆ្នាំបន្តបន្ទាប់ ផង ។ ជាក់ស្តែង, ខុសពីឆ្នាំ ២០២៤ ដែលថ្លៃស្រូវ-អង្ករ បានឡើងខ្ពស់, ក្នុងឆ្នាំ ២០២៥ នេះ, ថ្លៃស្រូវ-អង្ករ បានថមថយ ដោយសារកត្តាសត្យានុម័តមួយចំនួន រួមមាន៖ ការកើនឡើងនៃផលិតកម្មស្រូវជារួម ដោយសារក្តីរំពឹងនូវថ្លៃខ្ពស់, ការដកបម្រាមនៃការនាំចេញអង្កររបស់ឥណ្ឌា, ការចាប់ផ្តើមនាំអង្ករចេញឡើងវិញរបស់ប៉ាគីស្ថាន, ការបិទការនាំចូលអង្ករ សម្រាប់រយៈពេល ២ ខែ ពីសំណាក់ហ្វីលីពីន, និង ការបិទច្រកព្រំដែនគោក រវាងកម្ពុជា-ថៃ ។ល។ ជា

វិធានការចំពោះមុខ, ឯកឧត្តមរដ្ឋមន្ត្រី **ឌិត ទីណា** បានគូសបញ្ជាក់ ក្នុងចំណាប់អារម្មណ៍ នៅមុននេះហើយថា រាជរដ្ឋាភិបាល, ដោយមានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសេនាធិការ, បាន និង កំពុង ចាត់វិធានការ ប្រកបដោយភាពបុរេសកម្ម ដើម្បីគ្រប់គ្រង ស្ថានការណ៍នេះ ។

ជាការរួមចំណែកបន្ថែម, ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ ផ្តល់នូវអនុសាសន៍មួយចំនួន ដែលគ្រប់តួអង្គពាក់ព័ន្ធ ក្នុងវិស័យស្រូវ-អង្ករ, ពិសេស ក្រសួង-ស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាល និង សហព័ន្ធស្រូវ-អង្ករកម្ពុជា, ត្រូវបន្តរួមគ្នាយកចិត្តទុកដាក់ តាមសមត្ថកិច្ចរៀងៗខ្លួន ដូចខាងក្រោម៖

**ទី១. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**, ដោយមានកិច្ចសហការជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ត្រូវបន្តតាមដាននូវការវិវត្តនៃសភាពការណ៍ទីផ្សារស្រូវ-អង្ករ និង ចាត់វិធានការអន្តរាគមន៍ តាមរយៈយន្តការទាំងឡាយដែលរាជរដ្ឋាភិបាល បានដាក់ចេញរួចហើយ, ដូចខ្ញុំបានគូសបញ្ជាក់ខាងលើ, ឲ្យអស់លទ្ធភាព និង សក្តានុពល, ដើម្បីគ្រប់គ្រងស្ថានភាព ចំពោះមុខឲ្យបានប្រសើរ ។

**ទី២. ក្រសួងពាណិជ្ជកម្ម**, ដោយមានកិច្ចសហការជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ត្រូវជំរុញ និង តាមដានការអនុវត្ត «**យុទ្ធសាស្ត្រពង្រីក និង ពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា ២០២៥-២០៣០**» ដែលត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់ នាថ្ងៃនេះ ឲ្យមានប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពខ្ពស់ ។ ទន្ទឹមនេះ, សហព័ន្ធស្រូវ-អង្ករកម្ពុជា ក៏ត្រូវរៀបចំផែនការសកម្មភាពជាក់លាក់ ដើម្បីចូលរួមអនុវត្ត ឲ្យបានពេញលេញ ផងដែរ ។

**ទី៣. សហព័ន្ធស្រូវ-អង្ករកម្ពុជា**, ដោយមានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងពាណិជ្ជកម្ម, ត្រូវខិតខំវិនិយោគបន្ថែម ដើម្បីបន្តផ្សព្វផ្សាយ **«កិត្តិនាម»** របស់អង្ករកម្ពុជា ដែលជាកត្តាដ៏សំខាន់មួយ ក្នុងការនាំមកនូវភាពជោគជ័យ នៃការនាំចេញអង្ករ ទន្ទឹមនឹងការខិតខំកសាង នូវខ្សែច្រវាក់ផលិតកម្មស្រូវ-អង្ករ ដែលធានាបាននូវបរិមាណផ្គត់ផ្គង់ ដែលមានស្ថិរភាព, គុណភាព និង សុវត្ថិភាព ។

**ទី៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ** ត្រូវពង្រឹងការគ្រប់គ្រងផលិតកម្ម និង ធាតុចូលកសិកម្ម ដែលជាកត្តាដ៏សំខាន់ ដូចគ្នានឹងការគ្រប់គ្រងបរិមាណផល, ជាពិសេស ខណៈដែលកម្ពុជាឈានទៅសម្រេចបាន នូវផលិតកម្មក្នុងកម្រិតខ្ពស់សមល្មម និង ដោយហេតុថា ទីផ្សារស្រូវ-អង្ករ តែងមានអន្តរាគមន៍ពីរដ្ឋ; ដូច្នេះ, ការគ្រប់គ្រងបរិមាណផលតែម្ខាង គឺមិនទាន់គ្រប់គ្រាន់នោះទេ ។

**ទី៥. សហព័ន្ធស្រូវ-អង្ករកម្ពុជា**, ដោយមានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ត្រូវគ្រប់គ្រង និង ជំរុញការវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធ, ជាពិសេស នៅតាមសហគមន៍ដាំដុះ, សម្រាប់ការប្រមូលទិញស្រូវ ក្នុងរដូវប្រមូលផល ឲ្យបានគ្រប់គ្រាន់ និង មានលក្ខណៈបត់បែន ស្របតាមកាលៈទេសៈតម្រូវ ។ ការណ៍នេះ មិនគ្រាន់តែចូលរួមចំណែកដល់ការរក្សាស្ថិរភាពថ្លៃស្រូវប៉ុណ្ណោះទេ, ប៉ុន្តែ ថែមទាំងបង្កើនមូលដ្ឋានគ្រឹះ ដើម្បីធានាសន្តិសុខស្បៀង និង ជំរុញការនាំចេញ ទៀតផង ។

**ទី៦. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងពាណិជ្ជកម្ម**, ដោយមានកិច្ចសហការជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ត្រូវជំរុញការប្រើប្រាស់បច្ចេកវិទ្យា, ជាពិសេស បច្ចេកវិទ្យាឌីជីថល, ឲ្យបានជាអតិបរមា នៅគ្រប់ដំណាក់កាល ដើម្បីបន្តបង្កើនប្រសិទ្ធភាព ក្នុងគ្រប់ខ្សែច្រវាក់ទាំងអស់, ទាំងក្នុងដំណាក់កាលផលិតកម្ម, ដំណាក់កាលប្រមូលទិញ, ដំណាក់កាលកែច្នៃ, ដំណាក់កាលផ្គត់ផ្គង់, ទាំងក្នុងស្រុក និង សម្រាប់ការនាំចេញ ។ ទន្ទឹមនេះ, **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**, ដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ក៏ត្រូវបន្តជំរុញនវានុវត្ត និង ធ្វើសុភបរមានីយកម្ម លើមូលដ្ឋានបច្ចេកវិទ្យាឌីជីថល ដែលមានស្រាប់បច្ចុប្បន្ន ឲ្យកាន់តែមានភាពសមស្រប ក្នុងបរិការណ៍កម្ពុជា, ទាំងពូជថ្នាំកសិកម្ម, គ្រឿងយន្តកសិកម្ម, បរិក្ខារសម្ងួត, ឃ្លាំងស្តុក និង ហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធផ្សេងទៀត, ទន្ទឹមនឹងការខិតខំប្រើប្រាស់ឲ្យអស់លទ្ធភាព នូវអនុផលនៅគ្រប់ដំណាក់កាលនីមួយៗ ។

**ទី៧. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**, ដោយមានកិច្ចសហការជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ត្រូវលើកកម្ពស់ និង អភិវឌ្ឍសមត្ថភាពកសិករ ដើម្បីឲ្យក្លាយជាកសិករសហគ្រិន ក្នុងវិស័យស្រូវ-អង្ករទាំងមូល តាមរយៈការធ្វើស្ថាប័នីយកម្ម លើការលើកកម្ពស់ការអភិវឌ្ឍពូជស្រូវ, ការពង្រឹងខ្សែច្រវាក់ជីកសិកម្ម និង ថ្នាំកសិកម្ម, ការអភិវឌ្ឍ និង ការជំរុញការធ្វើពិពិធកម្មទីផ្សារ, ការពង្រីកសហគមន៍កសិកម្ម និង ការលើកកម្ពស់កិច្ចសន្យាកសិកម្ម និង ការលើកកម្ពស់ស្តង់ដាផលិតកម្មកែច្នៃ ។

**ទី៨. សហព័ន្ធស្រូវអង្ករកម្ពុជា**, ដោយមានការគាំទ្រពីក្រសួង-ស្ថាប័នពាក់ព័ន្ធ, ត្រូវបន្តកសាងនូវប្រព័ន្ធខ្សែច្រវាក់ផលិតកម្មស្រូវ-អង្ករកម្ពុជា ឲ្យក្លាយទៅជា «**ប្រព័ន្ធតួអង្គក្នុងខ្សែច្រវាក់តែមួយ**» ដែលគោរពផលប្រយោជន៍គ្នាទៅវិញទៅមក និង ការប្រកួតប្រជែងដោយសហការគ្នា ដើម្បីពង្រឹង «**ទីតាំង ឬ ចំណែកទីផ្សារកម្ពុជា**» ជាយុទ្ធសាស្ត្រ នៅក្នុងទីផ្សារស្រូវ-អង្ករសកល ក៏ដូចជា លើកកម្ពស់ការគោរពផលប្រយោជន៍កសិករជាចម្បង, ជាពិសេស កសិករខ្នាតតូច ។ និង

**ទី៩.** **ក្រុមការងារអន្តរក្រសួងជំរុញការនាំចេញផលិតផលកសិកម្ម និង កសិ-ឧស្សាហកម្មអាទិភាពនៅកម្ពុជា**, ស្ថិតក្រោមឆ័ត្រនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដែលទើបត្រូវបានបង្កើតឡើង, ត្រូវចាប់ផ្ដើមបំពេញតួនាទី និង ភារកិច្ច របស់ខ្លួន ឲ្យបានសកម្ម ដើម្បីពិនិត្យ, សិក្សា និង វាយតម្លៃ អំពីបញ្ហាប្រឈម ក្នុងវិស័យកសិកម្ម សំដៅត្រៀមចាត់វិធានការដាក់ញ្ញប់ ឲ្យបានទាន់ពេល ក្នុងស្មារតីបុរេសកម្ម ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពខ្ពស់ ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ជាថ្មីម្ដងទៀត, មុននឹងបញ្ចប់, ខ្ញុំសូមសម្ដែងនូវការអបអរសាទរ ចំពោះថ្នាក់ដឹកនាំនៃសហព័ន្ធស្រូវ-អង្ករកម្ពុជា, អាណត្តិទី ៥, ដែលទើបត្រូវបានសមាជិក-សមាជិកានៃសហព័ន្ធស្រូវ-អង្ករកម្ពុជា បោះឆ្នោតផ្ដល់សេចក្ដីទុកចិត្ត និង សូមអបអរសាទរ ចំពោះការរៀបចំមហាសន្និបាតបូកសរុបការងារ និង បិទបញ្ចប់ អាណត្តិទី ៤ របស់សហព័ន្ធស្រូវ-អង្ករកម្ពុជា ប្រកបដោយជោគជ័យ នាពេលនេះ ដែលសបញ្ជាក់ពីភាពរឹងមាំ និង និរន្តរភាពនៃស្ថាប័នសហព័ន្ធស្រូវ-អង្ករកម្ពុជា និង ជាគំរូល្អ សម្រាប់សហព័ន្ធផ្សេងទៀត, ទាំងក្នុងវិស័យកសិកម្ម ក៏ដូចជា ក្នុងវិស័យឧស្សាហកម្ម និង វិស័យផ្សេងទៀត ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី** បានសមប្រកបដោយសុខភាពល្អបរិបូរណ៌, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច, ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងៗខ្លួន ។

ខ្ញុំមានកិត្តិយស សូមប្រកាសបិទ **មហាសន្និបាតបូកសរុបការងារ និង បិទបញ្ចប់អាណត្តិទី ៤ របស់សហព័ន្ធស្រូវ-អង្ករកម្ពុជា ឆ្នាំ ២០២៥** នាពេលនេះ ៕

***សូមអរគុណ!***